# សហគមន៍ខ្មែរកម្ពុជាក្រោម

**KHMER KAMPUCHEA KROM COMMUNITY**

**LA COMMUNAUTÉ DU KHMER KAMPUCHEA KROM**


លេខ ១០/១០ ស.ខ.ក.ក.

## គោរពជូន

## ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

**កម្មវត្ថុ៖** សំណើសុំ សាលសន្និសីទចតុមុខ ធ្វើបុណ្យរាប់បាត្រព្រះសង្ឃ ១៩៤៩អង្គ

**យោង៖** លិខិតលេខ២៨៥ ភត.អធ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១០ របស់សាលារាជធានីភ្នំពេញ

តបតាមកម្មវត្ថុ និងយោងខាងលើខាងលើ ខ្ញុំសូមអនុញ្ញាតជំរាបជូនឯកឧត្តមរដ្ឋមន្ត្រីមេត្តាជ្រាបថា នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ខាងមុខ សហគមន៍ខ្មែរកម្ពុជាក្រោម និងរៀបចំពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន ១៩៤៩អង្គ ដើម្បីឧទ្ទិសកុសលប្រគេនព្រះវិញ្ញាណក្ខន្ធព្រះវីរសមណៈ ថ្វាយព្រះវិញ្ញាណក្ខន្ធព្រះវីរព្រះមហាក្សត្រ និងវិញ្ញាណក្ខន្ធវីរបុរស នារី វីរយុទ្ធជន វីរយុទ្ធនារីខ្មែរស្នេហាជាតិទាំងអស់ ដែលបានពលីជីវិត ក្នុងបុព្វហេតុជាតិ សាសនា និងទឹកដីខ្មែរ ជាពិសេសពូជសាសន៍ សាសនា និងទឹកដីខ្មែរកម្ពុជាក្រោមដូចរៀងរាល់ឆ្នាំ។

កម្មវិធីបុណ្យ និងប្រព្រឹត្តិទៅក្រោមព្រះអធិបតីភាពព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១០ ចាប់ពីម៉ោង៧ព្រឹក រហូតដល់ម៉ោង១២ថ្ងៃត្រង់ និងមានរាប់បាត្រព្រះសង្ឃ១៩៤៩អង្គ និងមានប្រជារាស្ត្រចូលរួមប្រមាណជាង២០០០នាក់។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាអនុញ្ញាតសាលសន្និសីទចតុមុខតាមការណែនាំរបស់សាលារាជធានីភ្នំពេញដល់សហគមន៍ខ្មែរកម្ពុជាក្រោម បានរៀបចំពិធីបុណ្យដូចបានជំរាបជូនខាងលើ ដោយអនុគ្រោះ។

សូមឯកឧត្តម ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

*រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១០*

ប្រធានក្រុមប្រឹក្សាសហគមន៍ខ្មែរកម្ពុជាក្រោម

ថាច់ សេដ្ឋា

ក្រុមប្រឹក្សារាជធានីភ្នំពេញ

អតីតសមាជិកព្រឹទ្ធសភា

*សូមភ្ជាប់មកជាមួយ*

*លិខិតសាលារាជធានីភ្នំពេញ០១ច្បាប់*


ទីស្នាក់ការបណ្តោះអាសន្នផ្ទះលេខ: 10B ផ្លូវលេខ 234 សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទលេខ: (៨៥៥) ១២ ៩០៨ ៨៨២ / ០៩០ ៧៧៧ ០០៧

E-mail: senthach2000@yahoo.com; Website: http//khmerkromngo.org

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលារាជធានីភ្នំពេញ**

**លេខ :** ៤៩៥ ភត.អធិ

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១០

**ជំរាបមក**

**លោក ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម**

**កម្មវត្ថុ** : ស្តីពីសំណើសុំទីធ្លាសួនច្បារមុខវត្តបុទុមវតី (អតីតរោងអាយ៉ៃ) ធ្វើបុណ្យរាប់បាត្រព្រះសង្ឃ ១៩៨៩ អង្គ ។

**យោង** : លិខិតលេខ ០៤/១០ ស.ខ.ក.ក ចុះថ្ងៃទី ០៧/៥/២០១០ របស់សហគមន៍ខ្មែរកម្ពុជាក្រោម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបលោកជ្រាបថា : ចំពោះករណីសំណើសុំទីធ្លាសួនច្បារមុខវត្តបុទុមវតី (អតីតរោងអាយ៉ៃ) រៀបចំពិធីបុណ្យរាប់បាត្រព្រះសង្ឃចំនួន ១៩៨៩អង្គ ដើម្បីឧទ្ទិសកុសលប្រគេនព្រះវិញ្ញាណក្ខន្ធព្រះវីរសមណៈ ថ្វាយព្រះវិញ្ញាណក្ខន្ធព្រះវីរព្រះមហាក្សត្រ និងវិញ្ញាណក្ខន្ធវីរបុរស នារី យុទ្ធជន យុទ្ធនារីខ្មែរស្នេហាជាតិទាំងអស់ ដែលបានពលីជីវិតក្នុងបុព្វហេតុជាតិ សាសនា និងទឹកដីខ្មែរ ជាពិសេសពូជសាសន៍ សាសនា និងទឹកដីខ្មែរកម្ពុជាក្រោម ក្រោមព្រះអធិបតីភាព ព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃព្រះករុណាព្រះបាទ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ដែលគ្រោងធ្វើនៅថ្ងៃទី ០៤/៦/២០១០ ចាប់ពីម៉ោង ០៧ព្រឹក រហូតដល់ម៉ោង ១២ថ្ងៃត្រង់ មានប្រជាពលរដ្ឋចូលរួមប្រមាណជាង ២.០០០នាក់ នោះ សាលារាជធានីភ្នំពេញមិនអនុញ្ញាតជូនទេ គួរលោកស្នើសុំក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ធ្វើនៅសាលសន្និសីទចតុមុខវិញ ដើម្បីងាយស្រួលក្នុងការការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ។

អាស្រ័យហេតុនេះ សូមលោកជ្រាប ។

ចម្លងជូន
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
  (ដើម្បីជូនជ្រាបជាព័ត៌មាន)
- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- សាលាខណ្ឌដូនពេញ
- ឯកសារ-កាលប្បវត្តិ

**អភិបាលរាជធានីភ្នំពេញ**

**កែប ជុតិមា**

ស ៦៩ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣-៧២២ ៧៣៩ / ៧២៤ ៥២៥ ទូរសារ : (៨៥៥) ២៣-៧២៥ ៦២៦